

# ជួយយើងដឹងពីអ្នកជម្ងឺរបស់យើងឱ្យកាន់តែច្រើន

នៅពេលយើងដឹងពីពូជសាសន៍ និង ជាតិពន្ធុរបស់លោកអ្នក  យើងនឹងសិក្សាកាន់តែច្រើនអំពីវប្បធម៌ និង ភាសារបស់លោកអ្នក។  នេះជួយយើងដឹងពីលោកអ្នកកាន់តែច្រើន និង លើកកម្ពស់ការថែទាំដែលយើងផ្តល់ឱ្យអ្នកជម្ងឺទាំងអស់។ ចាប់ផ្តើមនៅ ខែ មករា ឆ្នាំ ២០០៧  យើងនឹងសួរព័ត៌មានពូជសាសន៍ និង ជាតិពន្ធុពីអ្នកជម្ងឺទាំងអស់។



## តើលោកអ្នកមានជាតិពន្ធុអ្វី?

ជាតិពន្ធុរបស់លោកអ្នកសំដៅទៅលើប្រវត្តិ, កេរ្តិ៍ដំណែល, វប្បធម៌, ដូនតា ឬ អ្វីៗនៃប្រទេសដែលលោកអ្នកចាប់កំណើត ។ សូមឱ្យយើងដឹង ប្រសិនបើលោកអ្នកគឺជាជនជាតិហៃទី, វៀតណាម, ប្រេស៊ីល -ល- ។

## តើលោកអ្នកគឺជាជនជាតិអ៊ីស្ប៉ានិក,  ឡាទីន  ឬ  អេស្ប៉ាញ?

លោកអ្នកអាចជាជនជាតិអ៊ីស្ប៉ានិក, ឡាទីន ឬ អេស្ប៉ាញ ប្រសិនបើលោកអ្នក ឬ គ្រួសាររបស់លោកអ្នកមកពីប្រទេសនៅអាមេរិកឡាទីន ឬ ប្រទេសដែលនិយាយភាសាអេស្ប៉ាញផ្សេងទៀត ។ សូមឱ្យយើងដឹងប្រសិនបើលោកអ្នកគិតថាខ្លួនលោកអ្នកគឺជនជាតិអ៊ីស្ប៉ានិក, ឡាទីន ឬ អេស្ប៉ាញ ។

## តើលោកអ្នកមានពូជសាសន៍អ្វី?

ពូជសាសន៍របស់លោកអ្នកគឺជាក្រុម ឬ ក្រុមដែលលោកអ្នកកំណត់អត្តសញ្ញាណដោយសារមានចរិកលក្ខណៈរូបរាងស្រដៀងគ្នា ឬ មានដើមកំណើតសង្គម និង ភូមិសាស្ត្រស្រដៀងគ្នា ។ សូមឱ្យយើងដឹងប្រសិនបើលោកអ្នកគឺជាជនជាតិអាស៊ី, ជនជាតិស្បែកខ្មៅ, ជនជាតិស្បែកស -ល- ។



## ឧទាហរណ៍ :

ខ្ញុំឈ្មោះ John ។ ពូជសាសន៍របស់ខ្ញុំគឺអាស៊ី ហើយជាតិពន្ធុរបស់ខ្ញុំគឺបង់ក្លាដេស ។  
ខ្ញុំឈ្មោះ Claudia ។ ពូជសាសន៍របស់ខ្ញុំគឺស្បែកខ្មៅ ហើយជាតិពន្ធុរបស់ខ្ញុំគឺហៃទី និង ចាម៉ៃកា ។  
ខ្ញុំឈ្មោះ Ronaldo ។ ពូជសាសន៍របស់ខ្ញុំគឺស្បែកស និង ស្បែកខ្មៅ ហើយជាតិពន្ធុរបស់ខ្ញុំគឺប្រេស៊ីល ។  
ខ្ញុំឈ្មោះ Pat ។ ពូជសាសន៍របស់ខ្ញុំគឺស្បែកខ្មៅ ហើយជាតិពន្ធុរបស់ខ្ញុំគឺអាហ្វ្រិកអាមេរិកាំង ។  
ខ្ញុំឈ្មោះ Chris ។ ពូជសាសន៍របស់ខ្ញុំគឺស្បែកស ហើយជាតិពន្ធុរបស់ខ្ញុំគឺអ៊ីតាលី និង អាមេរិកាំង ។

## ដោយដឹងពីលោកអ្នកកាន់តែច្រើន  យើងអាចផ្តល់នូវការថែទាំកាន់តែប្រសើរដល់អ្នកជម្ងឺរបស់យើង

គោលបំណងរបស់យើងគឺដើម្បីបំពេញតាមតម្រូវការរបស់អ្នកជម្ងឺទាំងអស់ដែលយើងបម្រើ ។ ការសិក្សាបានបង្ហាញថាមានភាពខុសគ្នាលើសុខភាពក្នុងចំណោមក្រុមពូជសាសន៍ និង ជាតិពន្ធុផ្សេងៗ ។ យើងមិនដឹងពីបុព្វហេតុអ្វីដែលនាំឱ្យមានភាពខុសគ្នាទាំងនេះទេ ហើយយើងត្រូវការសិក្សាបន្ថែមទៀតអំពីពួកវា ។ យើងអាចបំពេញតម្រូវការរបស់សហគមន៍ដែលយើងបម្រើកាន់តែប្រសើរ ប្រសិនបើយើងដឹងពីពូជសាសន៍ ជាតិពន្ធុ វប្បធម៌ និង ភាសារបស់អ្នកជម្ងឺយើង ។ ព័ត៌មាននេះនឹងត្រូវបានប្រើប្រាស់ដើម្បីឱ្យប្រាកដថាអ្នកជម្ងឺទាំងអស់កំពុងទទួលការថែទាំដ៏សមស្របមានគុណភាពខ្ពស់បំផុតតែប៉ុណ្ណោះ ។



**លើកកម្ពស់សុខភាព
របស់យើងទាំងអស់គ្នា**

Insert hospital
logo here

Khmer